# ព្រះរាជក្រម

នស/រកម/០៣២០/ ០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែមីនាឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង



Media from www.moj.gov.kh resource from www.ocm.gov.kh

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម

**មាត្រា១ .-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរដ្ឋធានីហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២០

នស/រកម.០៣២០.០០៣

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍានា**



Media from www.moj.gov.kh resource from www.ocm.gov.kh

# សន្ធិសញ្ញា

# ស្តីពី

# ការផ្ទេរទណ្ឌិត

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# សាធារណរដ្ឋសង្គមនិយមវៀតណាម

# សន្ធិសញ្ញា
# ស្តីពី
# ការផ្ទេរទណ្ឌិត
# រវាង
# ព្រះរាជាណាចក្រកម្ពុជា
# និង
# សាធារណរដ្ឋសង្គមនិយមវៀតណាម

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅនេះហៅថា"ភាគី" សម្រាប់ភាគីនីមួយៗ ឬ "គូភាគី" សម្រាប់ភាគីទាំងពីរ)។

- ដោយបានពិចារណាលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលទាក់ទងនឹងការអនុវត្តច្បាប់របស់គូភាគី និងក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យអនុវត្តច្បាប់ និងសកម្មភាពក្នុងផ្នែកយុត្តិធម៌។

- ក្នុងគោលបំណងធ្វើកិច្ចសហប្រតិបត្តិការក្នុងការផ្ទេរទណ្ឌិត ដើម្បីផ្តល់ឱកាសដល់ទណ្ឌិតក្នុងការធ្វើសមាហរណកម្មទៅក្នុងសង្គម និង

- ក្នុងគោលបំណងធ្វើកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ។

បានព្រមព្រៀងដូចតទៅ៖

## មាត្រា ១
## និយមន័យ

គោលបំណងនៃសន្ធិសញ្ញានេះ ៖

១- "សាលក្រម" គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលប្រកាសទោស។

២- "ភាគីផ្ទេរ" គឺជាភាគីដែលទណ្ឌិតអាច ឬត្រូវបានផ្ទេរ។

៣- "ភាគីទទួល" គឺជាភាគីដែលទណ្ឌិតអាច ឬត្រូវបានទទួល។

៤- "ទណ្ឌិត" គឺជាជនដែលកំពុងអនុវត្តទោសនៅក្នុងពន្ធនាគារ មន្ទីរពេទ្យ ឬកន្លែងផ្សេងទៀតនៅក្នុងដែនដីនៃភាគីផ្ទេរ តាមសាលក្រមដែលបានប្រកាសដោយតុលាការនៃភាគីផ្ទេរ។

៥- "ទោស" គឺជាទោសដាក់ពន្ធនាគារមានកំណត់កាល ឬអស់មួយជីវិតតាមការប្រកាសរបស់តុលាការ។

៦- "ប្រជាពលរដ្ឋ" គឺជាបុគ្គលដែលមានសញ្ជាតិខ្មែរ ឬសញ្ជាតិវៀតណាម។



Media from www.moj.gov.kh resource from www.ocm.gov.kh

## មាត្រា ២
## គោលបំណងនៃសន្ធិសញ្ញា

១-គូភាគីព្រមព្រៀងផ្តល់ឱ្យគ្នាទៅវិញទៅមកនូវកិច្ចសហការឲ្យបានទូលំទូលាយបំផុត ក្នុងការផ្ទេរទណ្ឌិតដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ និងច្បាប់របស់ភាគីនីមួយៗ។

២-ទណ្ឌិតអាចត្រូវបានផ្ទេរពីដែនដីនៃភាគីផ្ទេរទៅដល់ដែនដីរបស់ភាគីទទួល ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះដើម្បីអនុវត្តទោសទាំងអស់ ឬមួយផ្នែកនៃទោសដែលបានប្រកាសចំពោះជននោះ។

## មាត្រា ៣
## អាជ្ញាធរកណ្តាល

១- សម្រាប់គោលបំណងក្នុងការអនុវត្តសន្ធិសញ្ញានេះ ភាគីនីមួយៗត្រូវចាត់តាំងអាជ្ញាធរកណ្តាល។

២- អាជ្ញាធរកណ្តាលរបស់ព្រះរាជាណាចក្រកម្ពុជាគឺ ក្រសួងយុត្តិធម៌។

អាជ្ញាធរកណ្តាលរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមគឺ ក្រសួងសន្តិសុខសាធារណៈ។

ភាគីណាមួយអាច ផ្លាស់ប្តូរអាជ្ញាធរកណ្តាលរបស់ខ្លួន ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត តាមរយៈបណ្តាញការទូត ឱ្យបានឆាប់ប្រសិនបើអាចធ្វើទៅបាន។

៣- អាជ្ញាធរកណ្តាលរបស់គូភាគី ត្រូវចាត់ចែងសំណើសុំផ្ទេរទណ្ឌិត ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ និងច្បាប់របស់ភាគីនីមួយៗ។

៤- អាជ្ញាធរកណ្តាលអាចធ្វើទំនាក់ទំនង សម្របសម្រួលដោយផ្ទាល់ ឬតាមរយៈបណ្តាញការទូត ទៅវិញទៅមកសម្រាប់គោលបំណងនៃសន្ធិសញ្ញានេះ។

## មាត្រា ៤
## លក្ខខណ្ឌក្នុងការផ្ទេរ

ទណ្ឌិតអាចត្រូវបានផ្ទេរតាមសន្ធិសញ្ញានេះក្នុងលក្ខខណ្ឌដូចតទៅ៖

១-អំពើសកម្ម ឬអកម្មដែលត្រូវបានប្រកាសទោសជាបទល្មើសតាមច្បាប់នៃភាគីទទួល ឬអាចជាបទល្មើស ប្រសិនបើបានប្រព្រឹត្តនៅលើដែនដីរបស់ភាគីទទួល។ លក្ខខណ្ឌនេះមិនអាចត្រូវបានយកទៅបកស្រាយដោយតម្រូវថា បទល្មើសដែលមានចែងក្នុងច្បាប់របស់គូភាគីជាបទល្មើសដូចគ្នា។

២-ទណ្ឌិត គឺជាប្រជាពលរដ្ឋរបស់ភាគីទទួល។

៣-នៅពេលដែលទទួលបានសំណើសុំផ្ទេរទណ្ឌិត ត្រូវនៅសល់រយៈពេលអនុវត្តទោសពន្ធនាគារយ៉ាងតិច ០១ (មួយ) ឆ្នាំ។ ក្នុងករណីពិសេសលក្ខខណ្ឌនេះ អាចត្រូវបានលើកលែងតាមការព្រមព្រៀងរបស់គូភាគី។

៤-សាលក្រមចូលជាស្ថាពរ និងមិនមាននីតិវិធីតាមផ្លូវច្បាប់ផ្សេងទៀតពាក់ព័ន្ធនឹងបុគ្គលនៅក្នុងដែនដីរបស់ភាគីផ្ទេរ និង

៥-ភាគីផ្ទេរ និងភាគីទទួល និងទណ្ឌិត សុទ្ធតែព្រមព្រៀងគ្នាចំពោះការផ្ទេរនេះ។ នៅក្នុងករណីដែលទណ្ឌិតអសមត្ថភាព សម្រាប់ផ្តល់ការយល់ព្រមដោយអនុលោមតាមច្បាប់របស់ភាគីផ្ទេរ ការយល់ព្រមអាចត្រូវបានផ្តល់ដោយអ្នកតំណាងស្របច្បាប់របស់ទណ្ឌិត។

## មាត្រា ៥
## មូលដ្ឋានក្នុងការបដិសេធការផ្ទេរ

អនុលោមតាមសន្ធិសញ្ញានេះ គូភាគីត្រូវបដិសេធក្នុងការផ្ទេរទណ្ឌិត ក្នុងករណីណាមួយដូចខាងក្រោម៖

១-នៅពេលដែលមានមូលដ្ឋានច្បាស់លាស់ដែលអាចជឿជាក់បានថា ទណ្ឌិតអាចត្រូវបានយកទៅធ្វើទារុណកម្ម សងសឹក ឬទទួលរងទណ្ឌកម្មសាហាវព្រៃផ្សៃ និងអមនុស្សធម៌ នៅក្នុងដែនដីនៃភាគីទទួល ឬ

២-ការផ្ទេរអាចបង្កឲ្យមានការអន្តរាយដល់អធិបតេយ្យភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍សំខាន់ផ្សេងទៀតរបស់ភាគី។

## មាត្រា ៦
## នីតិវិធីក្នុងការផ្ទេរ

១-គូភាគីត្រូវផ្តល់ព័ត៌មានដល់ទណ្ឌិតអំពីអត្ថន័យនៃសន្ធិសញ្ញានេះ។ ប្រសិនបើទណ្ឌិតមានបំណងស្នើសុំផ្ទេរ ទណ្ឌិតត្រូវបង្ហាញបំណងនេះជូនភាគីផ្ទេរ ឬភាគីទទួល ភាគីដែលបានដឹងពីបំណងនេះ ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។

២-សំណើសុំផ្ទេរអាចធ្វើឡើងដោយភាគីផ្ទេរ ឬភាគីទទួល ទៅកាន់ភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ និងត្រូវមានព័ត៌មានដូចខាងក្រោម៖

ក-គោត្តនាម និងនាម ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់ទណ្ឌិត

ខ-សញ្ជាតិ និងស្ថានភាពនៃកន្លែងស្នាក់នៅរបស់ទណ្ឌិត និង

គ-ទីតាំង និងអាសយដ្ឋានបច្ចុប្បន្នរបស់ទណ្ឌិត។

៣-នៅពេលដែលមានសំណើសុំផ្ទេរ ភាគីផ្ទេរត្រូវផ្តល់ឱ្យភាគីទទួលនូវព័ត៌មានដូចខាងក្រោម៖



Media from www.moj.gov.kh resource from www.ocm.gov.kh

ក-របាយការណ៍អំពីអង្គហេតុដែលជាមូលដ្ឋាននៃការកំណត់អំពីពិរុទ្ធភាព និងការប្រកាសទោស និងច្បាប់ជាធរមានដែលចែងអំពីបទល្មើសនោះ។

ខ-កាលបរិច្ឆេទបញ្ចប់ការអនុវត្តទោស ប្រសិនបើមាន និងរយៈពេលដែលទណ្ឌិតបានអនុវត្តទោសរួចហើយ ព្រមទាំងសេចក្តីសម្រេចបន្ធូរបន្ថយទោស ដែលទណ្ឌិតបានទទួលដោយផ្អែកលើលទ្ធផលការងារដែលបានបំពេញចប់សព្វគ្រប់ហើយ ដោយផ្អែកលើអាកប្បកិរិយាល្អរយៈពេលឃុំខ្លួនមុនពេលជំនុំជម្រះ ឬមូលហេតុផ្សេងទៀត។

គ-ច្បាប់ចម្លងសាលក្រមដោយមានការបញ្ជាក់។

ឃ-របាយការណ៍អំពីការកែប្រែ ស្ថានភាពសុខភាព ឬសង្គមដែលទាក់ទងនឹងទណ្ឌិត ព័ត៌មានលម្អិតអំពីដំណើរការនៃការព្យាបាលទណ្ឌិត នៅក្នុងដែនដីនៃភាគីផ្ទេរនិងអនុសាសន៍សម្រាប់ការព្យាបាលបន្តទៅលើទណ្ឌិតនោះ នៅក្នុងដែនដីនៃភាគីទទួលប្រសិនបើមាន។

ង-ឯកសារចម្លងនៃលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ ឬឯកសារផ្ទាល់ខ្លួនផ្សេងៗ ប្រសិនបើមាន រូបថត និងស្នាមម្រាមដៃ (ទាំងអស់) របស់ទណ្ឌិត និង

ច-ព័ត៌មានបន្ថែមទៀត ដែលស្នើសុំដោយភាគីទទួល។

៤-ប្រសិនបើមានសំណូមពររបស់ភាគីផ្ទេរ ភាគីទទួលត្រូវផ្តល់ឲ្យភាគីផ្ទេរនូវព័ត៌មានដូចខាងក្រោមមុនពេលផ្ទេរ៖

ក-ឯកសារ ឬសេចក្តីថ្លែងការណ៍បញ្ជាក់ថា ទណ្ឌិតនោះឆ្លើយតបពេញលេញតាមលក្ខខណ្ឌដែលបានបញ្ញត្តក្នុងកថាខណ្ឌទី២ នៃមាត្រា៤ នៃសន្ធិសញ្ញានេះ។

ខ-សេចក្តីថ្លែងការណ៍ដែលបញ្ជាក់ថា អំពើសកម្ម ឬអកម្មដែលត្រូវបានប្រកាសទោសជាបទល្មើសតាមច្បាប់នៃភាគីទទួល ឬអាចជាបទល្មើស ប្រសិនបើបានប្រព្រឹត្តនៅលើដែនដីរបស់ភាគីទទួល។

គ-សេចក្តីថ្លែងការណ៍អំពីវិធីសាស្ត្រដែលភាគីទទួលនឹងអនុវត្តទោសចំពោះទណ្ឌិត និង

ឃ-ព័ត៌មានបន្ថែមផ្សេងទៀត។

៥-ប្រសិនបើមានសំណើសុំ ភាគីត្រូវផ្តល់ទៅឱ្យភាគីម្ខាងទៀត ឲ្យអស់លទ្ធភាពនូវព័ត៌មាន ឯកសារ ឬសេចក្តីថ្លែងការណ៍ដែលពាក់ព័ន្ធ មុនពេលធ្វើសំណើសុំផ្ទេរ ឬសេចក្តីសម្រេចយល់ព្រម ឬមិនយល់ព្រមចំពោះការផ្ទេរ។

## មាត្រា ៧
## ការយល់ព្រមរបស់ទណ្ឌិត

១-ភាគីផ្ទេរ ត្រូវធានាថា ទណ្ឌិតបានយល់ព្រមចំពោះការផ្ទេរដោយស្ម័គ្រចិត្ត និងបានដឹងយ៉ាងច្បាស់ អំពីផលវិបាកខាងផ្លូវច្បាប់ដែលកើតចេញពីការផ្ទេរ។ នីតិវិធីផ្តល់ការយល់ព្រម អាស្រ័យ



5

Media from www.moj.gov.kh resource from www.ocm.gov.kh

ដោយការកំណត់របស់ច្បាប់នៃភាគីផ្ទេរ។

២-មុនពេលផ្ទេរ ប្រសិនបើមានការស្នើសុំពីភាគីទទួល ភាគីផ្ទេរត្រូវផ្តល់ឱកាសឱ្យ ភាគីទទួល ចាត់តាំងមន្ត្រីខ្លួនធ្វើការផ្ទៀងផ្ទាត់ការយល់ព្រមរបស់ទណ្ឌិតចំពោះការផ្ទេរ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត និងបានយល់ដឹងយ៉ាងល្អិតល្អន់អំពីផលវិបាកខាងផ្លូវច្បាប់ដែលអាចកើតមាន ស្របតាមកថាខណ្ឌទី៥ នៃមាត្រា៤ នៃសន្ធិសញ្ញានេះ។

## មាត្រា ៨
## ការសើរើលើសាលក្រម និងការលើកលែងទោសជាទូទៅ ការលើកលែងទោស ឬការបន្ធូរបន្ថយទោស

១-ភាគីផ្ទេរតែមួយគត់ ដែលមានសិទ្ធិសើរើសាលក្រម។

២-ភាគីណាមួយ អាចផ្តល់ការលើកលែងទោសជាទូទៅ ការលើកលែងទោស ឬការបន្ធូរបន្ថយទោស យោងតាមច្បាប់របស់ភាគីនោះ និងត្រូវជូនដំណឹងទៅភាគីម្ខាងទៀត អំពីសេចក្តីសម្រេចនេះភ្លាម តាមដែលអាចធ្វើទៅបាន។

## មាត្រា ៩
## អានុភាពនៃការផ្ទេរសម្រាប់ភាគីទទួល

១-អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួល ត្រូវបន្តការអនុវត្តទោសដោយសេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរដ្ឋបាល ប្រសិនបើមានតាមច្បាប់ជាតិ និងស្របតាមបណ្តាលក្ខខណ្ឌដែលបានបញ្ញត្តក្នុងមាត្រា១០ នៃសន្ធិសញ្ញានេះ។

២-ស្របតាមបទប្បញ្ញត្តិមាត្រា៨ នៃសន្ធិសញ្ញានេះ ការអនុវត្តទោស ត្រូវបានគ្រប់គ្រងដោយច្បាប់នៃភាគីទទួល និងមានតែភាគីនេះតែប៉ុណ្ណោះ មានសមត្ថកិច្ចអនុវត្តគ្រប់សេចក្តីសម្រេចសមស្រប។

## មាត្រា ១០
## ការបន្តការអនុវត្តទោស

១-ភាគីទទួល ត្រូវតែអនុវត្តទោសដែលបានប្រកាសដោយភាគីផ្ទេរ។

២-លើកលែងបញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ ការបន្តការអនុវត្តទោសក្រោយពេលផ្ទេរ ត្រូវអនុវត្តតាមច្បាប់ និងនីតិវិធីរបស់ភាគីទទួល។

៣-ប្រសិនបើប្រភេទ ឬរយៈពេលនៃទោសមិនស្របជាមួយច្បាប់របស់ភាគីទទួល នោះភាគីទទួល អាចសម្របសម្រួលទោសនោះឲ្យស្របជាមួយទោសដែលច្បាប់របស់ខ្លួនបានកំណត់ចំពោះបទល្មើសប្រហាក់ប្រហែលគ្នា។ នៅពេលមានការសម្របសម្រួលទោស អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួល ត្រូវផ្អែកលើសេចក្តីសន្និដ្ឋានអំពីអង្គហេតុក្នុងរឿងក្តីដែលបានពីយោបល់ពិរុទ្ធភាព សាលក្រម ឬទោសដែលត្រូវបានប្រកាសដោយភាគីផ្ទេរ។ ទោសដែលត្រូវបានសម្របសម្រួល មិនអាចធ្ងន់ជាងទោសដែលភាគីផ្ទេរបានប្រកាស ដោយផ្អែកលើប្រភេទ ឬរយៈពេល។ នៅពេលដែលមានការសម្របសម្រួលទោស អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួល មិនអាចប្តូរពីទោសដាក់ពន្ធនាគារទៅជាទោសមិនដកហូតសេរីភាពបានឡើយ។

៤-ប្រសិនបើទណ្ឌិតជាអនីតិជនតាមច្បាប់របស់ភាគីទទួល នោះភាគីទទួលអាចប្រព្រឹត្តទៅលើទណ្ឌិតនោះដូចជាអនីតិជន ដោយមិនគិតអំពីស្ថានភាពគតិយុត្តរបស់ទណ្ឌិតនោះដោយអនុលោមតាមច្បាប់របស់ភាគីផ្ទេរឡើយ។

៥-ភាគីទទួល ត្រូវអនុវត្តការបន្ធូរបន្ថយ ឬការលើកលែងទោសដល់ទណ្ឌិតនេះភ្លាម ក្រោយពេលទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់ភាគីផ្ទេរ ដោយអនុលោមតាមមាត្រា៨ នៃសន្ធិសញ្ញានេះ។

៦-គូភាគីត្រូវជូនដំណឹងដល់ទណ្ឌិតជាលាយលក្ខណ៍អក្សរអំពីរាល់ចំណាត់ការ ឬសេចក្តីសម្រេចរបស់ភាគីផ្ទេរ ឬភាគីទទួលតាមបញ្ញត្តិនៃកថាខណ្ឌទី២ ដល់កថាខណ្ឌទី៥ នៃមាត្រានេះ។

## មាត្រា ១១
## អានុភាពនៃការបញ្ចប់ការដាក់ទោសសម្រាប់ភាគីផ្ទេរ

នៅពេលភាគីទទួលជូនដំណឹងដល់ភាគីផ្ទេរ អំពីការអនុវត្តទោសដែលត្រូវបានបញ្ចប់ ដោយអនុលោមតាមកថាខណ្ឌទី២ នៃមាត្រា១២ នៃសន្ធិសញ្ញានេះ ការជូនដំណឹងនេះមានអានុភាពជាការរួចផុតពីទោសនៅភាគីផ្ទេរ។

## មាត្រា ១២
## ព័ត៌មានអំពីការអនុវត្តទោស

ភាគីទទួលត្រូវតែផ្តល់ព័ត៌មានដែលទាក់ទងនឹងការអនុវត្តទោសទៅភាគីផ្ទេរ ក្នុងករណីណាមួយដូចខាងក្រោម៖

១-ទណ្ឌិត បានទទួលការដោះលែងដោយមានលក្ខខណ្ឌ

២-ភាគីទទួល យល់ឃើញថាការអនុវត្តទោសត្រូវបានបញ្ចប់

៣-ភាគីទទួល សម្របសម្រួលទោសដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា១០ នៃសន្ធិសញ្ញានេះ

៤-ទណ្ឌិត បានលួចរត់ចេញពីទីឃុំឃាំង ឬប្រសិនបើទណ្ឌិតទទួលមរណភាពមុនពេលបញ្ចប់ការអនុវត្តទោស និង

៥-ភាគីផ្ទេរ ស្នើសុំរបាយការណ៍។

## មាត្រា ១៣
## ភាសា

សំណើសុំផ្ទេរ និងឯកសារពាក់ព័ន្ធត្រូវភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសាផ្លូវការរបស់ភាគីទទួល ឬជាភាសាអង់គ្លេស។

## មាត្រា ១៤
## ការចំណាយ

១-ភាគីទទួល ត្រូវទទួលបន្ទុកលើការចំណាយ ដូចជា៖

ក-ការផ្ទេរទណ្ឌិត លើកលែងការចំណាយដែលបានកើតនៅក្នុងដែនដីរបស់ភាគីផ្ទេរ និង

ខ-ការបន្តអនុវត្តទោសក្រោយពេលផ្ទេរ។

២-ទោះយ៉ាងណា ភាគីទទួលអាចប្រមូលមកវិញទាំងស្រុង ឬមួយផ្នែកនៃការចំណាយក្នុងការផ្ទេរពីទណ្ឌិត ឬពីប្រភពផ្សេងៗ។

## មាត្រា ១៥
## ការពិគ្រោះយោបល់

អាជ្ញាធរកណ្តាលនៃគូភាគី អាចពិគ្រោះយោបល់គ្នា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តសន្ធិសញ្ញានេះ និងព្រមព្រៀងអំពីវិធានការជាក់ស្តែងចាំបាច់ ដើម្បីផ្តល់ភាពងាយស្រួលដល់ការអនុវត្តសន្ធិសញ្ញានេះ។

## មាត្រា ១៦
## ការដោះស្រាយជំនាស់

១-គូភាគីត្រូវស្វែងរកដំណោះស្រាយរាល់វិវាទដែលកើតចេញពីការបកស្រាយ ការអនុវត្ត ឬការប្រតិបត្តិសន្ធិសញ្ញានេះ តាមរយៈអាជ្ញាធរកណ្តាល។



Media from www.moj.gov.kh resource from www.ocm.gov.kh

២-ប្រសិនបើអាជ្ញាធរកណ្តាលមិនមានលទ្ធភាពដោះស្រាយវិវាទ ដូចដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះទេ គូភាគីត្រូវស្វែងរកដំណោះស្រាយវិវាទនេះ តាមរយៈបណ្តាញការទូត។

## មាត្រា ១៧
## ភាតព្វកិច្ចនៅក្រោមសន្ធិសញ្ញាអន្តរជាតិ

សន្ធិសញ្ញានេះ មិនមានឥទ្ធិពលទៅលើសិទ្ធិ ឬកាតព្វកិច្ចនៃគូភាគីដែលជាសមាជិកនៃសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតឡើយ។

## មាត្រា ១៨
## ការប្រគល់ ទទួលទណ្ឌិត

១-ការប្រគល់ ទទួលទណ្ឌិតពីភាគីផ្ទេរដល់ភាគីទទួល ត្រូវធ្វើឡើងនៅទីកន្លែង និងពេលវេលាដែលគូភាគីបានព្រមព្រៀង។ ភាគីទទួល ត្រូវទទួលខុសត្រូវចំពោះការដឹកជញ្ជូនទណ្ឌិតពីភាគីផ្ទេរ និងត្រូវទទួលខុសត្រូវលើការឃុំឃាំងទណ្ឌិត នៅក្រៅដែនដីរបស់ភាគីផ្ទេរ។

២-ការប្រគល់ ទទួលទណ្ឌិត ត្រូវធ្វើជាលាយលក្ខណ៍អក្សរចំនួនពីរច្បាប់ ជាភាសាខ្មែរ ភាសាវៀតណាម និងភាសាអង់គ្លេស ដែលគ្រប់អត្ថបទទាំងអស់មានតម្លៃស្មើគ្នា។ ភាគីនីមួយៗ ត្រូវរក្សាទុកមួយច្បាប់។

## មាត្រា ១៩
## វិសោធនកម្ម

រាល់ការធ្វើវិសោធនកម្ម ឬការកែប្រែសន្ធិសញ្ញានេះ ដែលបានទទួលការយល់ព្រមពីគូភាគី ត្រូវចូលជាធរមានតាមរបៀបដូចគ្នា ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា២០ នៃសន្ធិសញ្ញានេះ។

## មាត្រា ២០
## អវសានប្បញ្ញត្តិ

១-សន្ធិសញ្ញានេះ ត្រូវជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន។ ភាគីនីមួយៗ ត្រូវជូនដំណឹងទៅវិញទៅមកឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ជាលាយលក្ខណ៍អក្សរ តាមរយៈបណ្តាញការទូត អំពីការបញ្ចប់នីតិវិធីគតិយុត្ត ដែលចាំបាច់សម្រាប់ការចូលជាធរមាននៃសន្ធិសញ្ញានេះ។ សន្ធិសញ្ញា

10/05/2021



នេះ ត្រូវមានអានុភាពអនុវត្តនៅថ្ងៃទីមួយ នៃខែទីពីរ គិតពីកាលបរិច្ឆេទទទួលបានការជូនដំណឹងចុងក្រោយ។

២-សន្ធិសញ្ញានេះ មានអានុភាពអនុវត្តដោយគ្មានកំណត់ពេល។ ប៉ុន្តែសន្ធិសញ្ញានេះ អាចត្រូវបានបញ្ចប់អានុភាព ដោយភាគីណាមួយ ជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរតាមរយៈបណ្តាញការទូត។ ការបញ្ចប់នេះ នឹងមានអានុភាពក្រោយរយៈពេលប្រាំមួយ (៦) ខែ គិតពីកាលបរិច្ឆេទទទួលបានការជូនដំណឹងនេះ។

៣-ទោះបីមានការបញ្ចប់សន្ធិសញ្ញានេះក៏ដោយ សន្ធិសញ្ញានេះនៅតែបន្តអនុវត្តចំពោះសំណើសុំផ្ទេរទណ្ឌិតដែលបានធ្វើមុនកាលបរិច្ឆេទនៃការបញ្ចប់សន្ធិសញ្ញានេះ មានអានុភាព។

៤-សន្ធិសញ្ញានេះ ត្រូវយកទៅអនុវត្តចំពោះទោសដែលបានប្រកាសមុន ឬក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃសន្ធិសញ្ញានេះ។

ដើម្បីជាសក្ខីភាពនៅក្នុងសន្ធិសញ្ញានេះ អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញដោយព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ។

ធ្វើនៅរដ្ឋធានីហាណូយ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៦ ធ្វើឡើងជាពីរច្បាប់ជាភាសាខ្មែរ ភាសាវៀតណាម និងភាសាអង់គ្លេស ដែលគ្រប់អត្ថបទទាំងអស់មានតម្លៃស្មើគ្នា។ ក្នុងករណីមានវិវាទ ឬការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេស ត្រូវយកប្រើប្រាស់ជាអត្ថបទគោល។

**តំណាងព្រះរាជាណាចក្រកម្ពុជា** **តំណាងសាធារណរដ្ឋសង្គមនិយមវៀតណាម**





**អង្គ វង្ស វឌ្ឍនា**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ឡេ មិញ ជី**
**ឧត្តមរដ្ឋអាជ្ញាប្រជាជនកំពូល**



Media from www.moj.gov.kh resource from www.ocm.gov.kh

# TREATY

# ON

# THE TRANSFER OF SENTENCED PERSONS

# BETWEEN

# THE KINGDOM OF CAMBODIA

# AND

# THE SOCIALIST REPUBLIC OF VIET NAM

5

# TREATY

# ON

# THE TRANSFER OF SENTENCED PERSONS

# BETWEEN

# THE KINGDOM OF CAMBODIA

# AND

# THE SOCIALIST REPUBLIC OF VIET NAM

The Kingdom of Cambodia and the Socialist Republic of Viet Nam (hereinafter referred to individually as 'the Party' and collectively as 'the Parties');

*Taking into consideration* the laws and regulations in force regarding law enforcement of the Parties and the desirability of enhancing their cooperative efforts in law enforcement and the administration of justice;

*Desiring* to co-operate in the transfer of sentenced persons to facilitate their successful reintegration into society; and

*Desiring* to co-operate in the enforcement of penal sentences;

Have agreed as follows:

## ARTICLE 1
## DEFINITIONS

For the purposes of this Treaty:

1. "Judgment" means a decision of a court imposing a sentence;

2. "Transferring Party" means the Party from which the sentenced person may be, or has been transferred;

3. "Receiving Party" means the Party to which the sentenced person may be, or has been transferred;

4. "Sentenced person" means a person who is serving the imprisonment in a prison, a hospital or any other place in the territory of the transferring Party under a sentence imposed by a court of the transferring Party;



5 ∽ 

5. "Sentence" means imprisonment for a period or life imprisonment ordered by a court;

6. "National" means a person who has nationality of Cambodia or Viet Nam.

## ARTICLE 2
## PURPOSE OF TREATY

1. The Parties undertake to afford each other the widest measure of cooperation in respect of the transfer of sentenced persons in accordance with the provisions of this Treaty and the law of each Party.

2. A sentenced person may be transferred from the territory of the transferring Party to the territory of the receiving Party in accordance with the provisions of this Treaty in order to serve the whole or part of the sentence imposed on him or her.

## ARTICLE 3
## CENTRAL AUTHORITIES

1. For the purpose of implementing this Treaty, each Party shall designate a Central Authority.

2. The Central Authority for the Kingdom of Cambodia is the Ministry of Justice. The Central Authority for the Socialist Republic of Viet Nam is the Ministry of Public Security. Either Party may change its Central Authority in which case it shall notify in writing the other of the change through diplomatic channels as soon as possible.

3. The Central Authorities of the Parties shall process requests for transfer in accordance with the provisions of this Treaty and the law of each Party.

4. The Central Authorities may communicate, co-ordinate directly or through diplomatic channels with each other for the purposes of this Treaty.

## ARTICLE 4
## CONDITIONS FOR TRANSFER

A sentenced person may be transferred under this Treaty only on the following conditions:

1. The acts or omissions on account of which the sentence has been



5 ý

imposed constitute a criminal offence according to the law of the receiving Party, or would constitute such a criminal offence if committed on the territory of the receiving Party. This condition shall not be interpreted to require that the offence described in the laws of both Parties be identical;

2. The sentenced person is a national of the receiving Party;

3. The sentenced person has at least one (01) year remaining to be served at the time of receipt of the request for transfer. In exceptional cases, this requirement may be waived by agreement of the Parties;

4. The judgment is final and no other legal proceedings pending in respect of this person in the territory of the transferring Party; and

5. The transferring and receiving Parties and the sentenced person all consent to the transfer. Where the sentenced person is incapable of giving consent under the law of the transferring Party, consent may be given by a person entitled to act on their behalf.

## ARTICLE 5
## GROUNDS FOR REFUSAL OF TRANSFER

Under this Treaty, the Parties shall refuse to transfer a person who is serving a sentence in any of the following circumstances:

1. There are grounds to believe that the sentenced person would be subjected to torture, retaliation, treated or punished brutally and inhumanly in the receiving Party; or

2. The transfer would prejudice sovereignty, national security, public order or other essential interests of the Party.

## ARTICLE 6
## PROCEDURE FOR TRANSFER

1. The Parties shall endeavour to inform sentenced persons of the substance of this Treaty. If the sentenced person wishes to be transferred, they may express such a wish to the transferring Party or the receiving Party, either of whom must inform the other Party in writing.

2. A request for transfer may be made by the transferring Party or the receiving Party to the other Party and shall be in writing and shall include the following information:

a) The full name, day, month, year and place of birth of the sentenced



Media from www.moj.gov.kh resource from www.ocm.gov.kh

person;

b) The nationality and residence status of the sentenced person; and

c) The location and current address of the sentenced person.

3. Where a request for transfer has been made, the transferring Party shall provide the receiving Party with the following information:

a) A statement of the facts upon which the conviction and sentence were based and a statement of the applicable law creating the offence;

b) The termination date of the sentence, if applicable, and the length of time already served by the sentenced person and any remissions to which they are entitled on account of work done, good behaviour, pre-trial confinement or other reasons;

c) A certified copy of the judgment;

d) Any corrections, medical or social reports on the sentenced person, information about their treatment in the transferring Party, and any recommendation for their further treatment in the receiving Party, if applicable;

e) A copy of passport or identification card or any other personal documents, if applicable, the photo and finger prints (all fingers) of the sentenced person; and

f) Any other additional information requested by the receiving Party.

4. The receiving Party must provide the transferring Party with the following information before transfer, if requested by the transferring Party:

a) A document or statement indicating that the sentenced person complies with the conditions in paragraph 2 of Article 4 of this Treaty;

b) A statement that the acts or omissions on account of which the sentence has been imposed constitute a criminal offence according to the law of the receiving Party or would constitute such a criminal offence if committed on the territory of the receiving Party;

c) A statement describing how the sentenced person's sentence would be enforced by the receiving Party; and

d) Any other additional information.

5. Either Party shall, as far as possible, provide the other Party, if it so requests, with any relevant information, documents or statements before making a request for transfer or making a decision on whether or not to agree to a transfer.



Media from www.moj.gov.kh resource from www.ocm.gov.kh

## ARTICLE 7
## CONSENT OF THE SENTENCED PERSON

1. The transferring Party shall ensure that the sentenced person consents to the transfer voluntarily and with full knowledge of the legal consequences thereof. The procedure for giving such consent shall be governed by the law of the transferring Party.

2. The transferring Party shall afford an opportunity to the receiving Party, if the receiving Party so desires, to verify through officials designated by the receiving Party, prior to the transfer, that the sentenced person's consent to the transfer in accordance with paragraph 5 of Article 4 of this Treaty is given voluntarily and with full knowledge of the legal consequences thereof.

## ARTICLE 8
## REVIEW OF JUDGMENT AND PARDON, AMNESTY OR COMMUTATION

1. The transferring Party alone shall decide on any application for review of the judgment.

2. Either Party may grant pardon, amnesty or commutation of the sentence in accordance with the law of that Party and shall inform other Party of this decision as soon as possible.

## ARTICLE 9
## EFFECT OF TRANSFER FOR THE RECEIVING PARTY

1. The competent authorities of the receiving Party shall continue the enforcement of the sentence through a court, administrative order, if available, as may be required under its national law, under the conditions set out in Article 10 of this Treaty.

2. Subject to the provisions of Article 8 of this Treaty, the enforcement of the sentence shall be governed by the law of the receiving Party and that Party alone shall be competent to make all appropriate decisions.



5

Media from www.moj.gov.kh resource from www.ocm.gov.kh

## ARTICLE 10
## CONTINUED ENFORCEMENT OF SENTENCE

1. The receiving Party shall enforce the sentence as imposed by the transferring Party.

2. Notwithstanding the requirements of paragraph 3 of this Article, the continued enforcement of the sentence after transfer shall be governed by the law and procedures of the receiving Party.

3. If the sentence is by its nature or duration incompatible with the law of the receiving Party, the receiving Party may adapt the sentence in accordance with the sentence prescribed by its own law for a similar offence. When adapting the sentence, the appropriate authorities of the receiving Party shall be bound by the findings of fact, insofar as they appear from any opinion, conviction, judgment, or sentence imposed by the transferring Party. The adapted sentence shall be no more severe than that imposed by the transferring Party in terms of nature or duration. When adapting the sentence, the competent authority of the receiving Party shall not convert an imprisonment punishment to a non-deprivation of liberty sanction.

4. The receiving Party may, if a sentenced person is a juvenile according to its law, treat the sentenced person as a juvenile regardless of their status under the law of the transferring Party.

5. The receiving Party shall modify or terminate enforcement of the sentence as soon as it is informed of any decisions by the transferring Party in accordance with Article 8 of this Treaty.

6. The Parties shall inform the sentenced person in writing of any action or decisions taken by the transferring Party or the receiving Party under paragraphs 2 to 5 of this Article.

## ARTICLE 11
## EFFECT OF COMPLETION OF SENTENCE FOR THE TRANSFERRING PARTY

When the receiving Party notifies the transferring Party under paragraph 2 of Article 12 of this Treaty that the sentence has been completed, such notification shall have the effect of discharging the sentence in the transferring Party.

**ARTICLE 12**
**INFORMATION ON ENFORCEMENT OF SENTENCE**

The receiving Party shall provide information to the transferring Party concerning enforcement of the sentence in one of the followings:

1. The sentenced person is granted conditional release;
2. It considers enforcement of the sentence to have been completed;
3. It adapts the sentence as stipulated in paragraph 3 of Article 10 of this Treaty;
4. The sentenced person has escaped from custody, or if the sentenced person dies, before enforcement of the sentence has been completed; and
5. The transferring Party requests a report.

**ARTICLE 13**
**LANGUAGE**

Requests for transfer and accompanying documents shall be accompanied by a translation into an official language of the receiving Party or English.

**ARTICLE 14**
**EXPENSES**

1. The receiving Party shall bear the expenses of:

a) The transfer of the sentenced person, except the expenses incurred exclusively in the territory of the transferring Party; and

b) The continued enforcement of the sentence after transfer.

2. The receiving Party may, however, seek to recover all or part of the cost of transfer from the sentenced person or other sources.

**ARTICLE 15**
**CONSULTATION**

The Central Authorities of the Parties may consult with each other to promote the most effective use of this Treaty and to agree upon such practical measures as may be necessary to facilitate the implementation of this Treaty.



Media from www.moj.gov.kh resource from www.ocm.gov.kh

## ARTICLE 16
## SETTLEMENT OF DISPUTES

1. The Parties shall seek to resolve any dispute arising out of the interpretation, application or implementation of this Treaty through the Central Authorities.

2. If the Central Authorities are unable to resolve a dispute as envisaged in paragraph 1 of this Article, the Parties shall seek to resolve the dispute through diplomatic channels.

## ARTICLE 17
## OBLIGATIONS UNDER INTERNATIONAL TREATIES

This Treaty shall not affect the rights or obligations of the Parties under international treaties or other agreements to which they are a party.

## ARTICLE 18
## HANDING OVER OF SENTENCED PERSONS

1. The handing over of the sentenced person by the transferring Party to the receiving Party shall occur at a place and time to be agreed upon between the Parties. The receiving Party shall be responsible for the transport of the sentenced person from the transferring Party and shall also be responsible for custody of the sentenced person outside the territory of the transferring Party.

2. The handing over of the sentenced person shall be made in writing, in duplicate, in Khmer, Vietnamese and English languages; all texts being equally authentic. Each Party shall keep one text.

## ARTICLE 19
## AMENDMENTS

Any amendments or modifications to this Treaty agreed to by the Parties shall come into force in the same manner as stipulated in paragraph 1 of Article 20 of this Treaty.



5

Media from www.moj.gov.kh resource from www.ocm.gov.kh

## ARTICLE 20
## FINAL PROVISIONS

1. This Treaty shall be subject to ratification. Each Party shall notify the other as soon as possible, in writing, through diplomatic channels, upon the completion of its legal procedures required for the entry into force of this Treaty. The Treaty shall come into force on the first day of the second month from the date of receipt of the last notification.

2. The Treaty shall remain in force for an indefinite period. It may, however, be terminated by either of the Party by giving a written notice of termination to other Party through diplomatic channels. The termination shall take effect after six (06) months from the date of receipt of such a notice.

3. Notwithstanding any termination, this Treaty shall continue to apply to the requests for transfer that made previously before the date on which such termination takes effect.

4. This Treaty shall apply to execution of sentences imposed before or after the date of entry into force of this Treaty.

In witness whereof, the undersigned, being duly authorized by the Kingdom of Cambodia and the Socialist Republic of Viet Nam, have signed this Treaty.

Done in the city of Ha Noi on 20th December 2016, in duplicate, in Khmer, Vietnamese and English languages; all texts being equally authentic. In case of any conflict or different interpretation, the English text shall prevail.

| FOR THE KINGDOM OF CAMBODIA | FOR THE SOCIALIST REPUBLIC OF VIET NAM |
|---|---|
| Ang Vong Vathana<br>Minister of Justice | Le Minh Tri<br>Prosecutor General of the Supreme People's Procuracy |



Media from www.moj.gov.kh resource from www.ocm.gov.kh

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

N° 108 D.F.P

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

Phnom Penh, December 13 2016

**DELEGATION OF FULL POWERS**

- Considering the Constitution of the Kingdom of Cambodia;
- Considering the Royal Decree NS/RKT/0913/903 dated 24 September 2013 on the Nomination of the Royal Government of Cambodia;
- Considering the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers;
- Considering the Royal Kram NS/RKM/0196/04 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Justice; and
- Pursuant to the Proposal of the Minister of Justice;

**THE ROYAL GOVERNMENT**

Delegates herewith Full Powers to **H.E ANG VONG VATHANA**, Minister of Justice, to sign Treaty between the Kingdom of Cambodia and the Socialist Republic of Viet Nam on Mutual Legal Assistance in Criminal matters and Treaty between Kingdom of Cambodia and the Socialist Republic of Viet Nam on the Transfer Sentenced Persons, which will be held on the occasion of the official visit of **Samdach Akka Moha Sena Padei Techo Prime Minister** from 20-21 December 2016 in Viet Nam.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

**Prime Minister**

**Samdech Akka Moha Sena Padei Techo HUN SEN**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១០៧...ស.ប.ទ

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ២០១៦

# សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូនឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសទស្សនកិច្ចការងាររបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចាប់ពីថ្ងៃទី២០-២១ ខែធ្នូ ឆ្នាំ២០១៦ នៅប្រទេសវៀតណាម។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់បានចុះហត្ថលេខាខាងក្រោម លើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**